សេចក្តីថ្លែងការណ៍រួម

## សូមដោះលែងទាហានកម្ពុជាចំនួន ១៨ នាក់ ដែលត្រូវបានចាប់ខ្លួន

រាជធានីភ្នំពេញ និង បាងកក ថ្ងៃសុក្រ ទី ២៩ ខែសីហា ឆ្នាំ ២០២៥

យើងខ្ញុំ ជាក្រុមសង្គមស៊ីវិលកម្ពុជា និងថៃ ដូចមានរាយនាមខាងក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាលថៃ សូមដោះលែងទាហានកម្ពុជាចំនួន ១៨ នាក់ ជាបន្ទាន់ និងឥតលក្ខខណ្ឌ ដើម្បីឱ្យអ្នកទាំងនោះអាចត្រឡប់មកជួបជុំក្រុមគ្រួសារ និងមនុស្សជាទីស្រឡាញ់របស់ពួកគេ នៅក្នុងប្រទេសវិញ ។ គិតត្រឹមថ្ងៃនេះ ទាហានកម្ពុជាទាំង ១៨ នាក់ ត្រូវបានចាប់ និងឃុំខ្លួននៅក្នុងប្រទេសថៃ អស់រយៈពេល ១ ខែ មកហើយ ។

ទាហានទាំង ១៨ នាក់ ត្រូវបានក្រុមទាហានថៃចាប់ខ្លួន កាលពីថ្ងៃទី ២៩ កក្កដា ២០២៥ ហើយអ្នកទាំងនោះត្រូវបានកងទ័ពភូមិន្ទថៃ និងក្រសួងការបរទេសថៃ ចាត់ទុកថាជាអ្នកទោសសង្គ្រាម ឬឈ្លើយសឹក (POWs) ។ យើងមានសេចក្តីសោមនស្ស ដែលកងទ័ពថៃ បានសម្របសម្រួល និងអនុញ្ញាតឱ្យកាកបាទក្រហមអន្តរជាតិ (ICRC) សួរសុខទុក្ខទាហានកម្ពុជាទាំង ១៨ នាក់នេះ ។ ក៏ប៉ុន្តែ ទាហានកម្ពុជាទាំងនោះ ត្រូវតែត្រូវបានដោះលែងភ្លាមៗ ក្រោយពេលចប់សង្គ្រាម ឬជម្លោះប្រដាប់អាវុធ ។ ភាគីកម្ពុជា និងថៃ បានព្រមព្រៀងឱ្យមានបទឈប់បាញ់ តាំងពីថ្ងៃទី ២៨ ខែកក្កដា មកម្ល៉េះ ។ ដូចនេះ ទាហានកម្ពុជាទាំងនោះ ត្រូវតែដោះលែង និងបញ្ជូនត្រឡប់មកកម្ពុជាវិញ ។

ការបន្តឃុំខ្លួនទាហានកម្ពុជាទាំងនេះ គ្រាន់តែជាការបន្តបញ្ឆេះភាពតានតឹងរវាងប្រទេសទាំងពីរ និងរាំងដំណើរការផ្សះផ្សារវាងប្រទេសជិតខាងទាំងពីរ ដែលត្រូវធ្វើ ដើម្បីកសាងសុខសន្តិភាពរួមគ្នាមួយដែលឋិតថេរ និងយូរអង្វែងតទៅ ។ យើងខ្ញុំសូមអំពាវនាវដល់កងទ័ពភូមិន្ទថៃ និងរាជរដ្ឋាភិបាលថៃ សូមចាត់វិធានការចាំបាច់ ដើម្បីសុខសន្តិភាព ដោយត្រូវដោះលែង និងបញ្ជូនទាហានកម្ពុជាទាំង ១៨ នាក់ ត្រឡប់មកកម្ពុជាវិញ ជាបន្ទាន់ ៕

เชลยศึกกัมพูชา 18 คนต้องได้รับการปลดปล่อย

กรุงเทพ/พนมเปญ, 29 สิงหาคม 2568

พวกเรา ภาคประชาสังคมกัมพูชาและไทยลงนามร่วมกัน เรียกร้องให้รัฐบาลไทยปล่อยตัวทหารกัมพูชา 18 นาย โดยทันทีและอย่างไม่มีเงื่อนไข หลังจากที่ถูกควบคุมตัวในประเทศไทยมาแล้วเป็นเวลาหนึ่งเดือนในวันนี้ เพื่อให้พวกเขาสามารถเดินทางกลับประเทศและพบกับครอบครัวและบุคคลอันเป็นที่รัก

ทหารทั้ง 18 นายถูกควบคุมตัวเมื่อวันที่ 29 กรกฎาคม 2568 กองทัพบกและกระทรวงการต่างประเทศไทยได้ระบุสถานะของพวกเขาว่าเป็นเชลยศึก (Prisoners of War) เรายินดีที่กองทัพบกไทยได้อำนวยความสะดวกให้คณะกรรมการกาชาดระหว่างประเทศ (International Committee of the Red Cross) เข้าเยี่ยมทหารเหล่านี้ อย่างไรก็ตาม เชลยศึกต้องได้รับการปล่อยตัวเมื่อการสู้รบสิ้นสุดลง ประเทศกัมพูชาและไทยมีข้อตกลงหยุดยิงตั้งแต่วันที่ 28 กรกฎาคมที่ผ่านมา กัมพูชาเหล่านี้จึงต้องถูกส่งกลับไปยังบ้านเกิด

การคุมตัวทหารกัมพูชาไว้ต่อไป จะยิ่งจุดชนวนความตึงเครียดระหว่างสองฝ่าย และขัดขวางกระบวนการเจรจาสมานฉันท์ ที่ประเทศเพื่อนบ้านทั้งสองจำเป็นต้องดำเนินการเพื่อสร้างสันติภาพที่ยาวนานและยั่งยืน พวกเราจึงขอเรียกร้องให้กองทัพบกและรัฐบาลไทยดำเนินการก้าวสำคัญในการส่งเสริมสันติภาพ โดยการปล่อยตัวและส่งทหารกัมพูชาทั้ง 18 นายกลับประเทศอย่างทันที

Release the 18 Cambodian Prisoners of War

Bangkok/Phnom Penh, Friday, 29 August 2025

We, the undersigned Cambodian and Thai civil society groups, urge the Thai government to immediately and unconditionally release the 18 Cambodian soldiers who are today marking one month of detention in Thailand, allowing them to return to their country and reunite with their families and loved ones.

The 18 soldiers were taken into custody on 29 July 2025. The Royal Thai Army and the Thai Ministry of Foreign Affairs have identified them as Prisoners of War (POWs). We are encouraged that the Thai army facilitated the International Committee of the Red Cross to visit these soldiers. However, POWs must be released at the end of active hostilities. Cambodia and Thailand have now had a ceasefire since 28 July. These soldiers must be returned home.

The ongoing detention of these men only serves to inflame tensions on both sides and prevents the reconciliation that both neighbours need to undergo in order to build a lasting and sustainable peace. We urge the Royal Thai Army and Thai government to take an important step toward promoting peace by releasing and returning the 18 Cambodian soldiers immediately.

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ ៖**

១. សហគមន៍ព្រៃឈើ ១៨៥កាធីតាចំបក់ (កំពង់ឆ្នាំង)
២. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
៣. សហគមន៍ កសិកម្ម និងអភិវឌ្ឍន៍ដើម្បីសន្តិភាព (ADCP)
៤. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
៥. សហគមន៍បឹងពីរ (បាត់ដំបង)
៦. សហគមន៍បឹងប្រាំ (បាត់ដំបង)
៧. សហគមន៍បុស្សស្នោរ (ត្បូងឃ្មុំ)
៨. សហព័ន្ធសហជីពកម្ពុជា (CATU)
៩. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១០. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ (CCIM)
១១. អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ (CHEC)
១២. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
១៣. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)

១៤. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
១៥. អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS)
១៦. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
១៧. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
១៨. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
១៩. សហគមន៍ដីធ្លីដីខក្រោម (កោះកុង)
២០. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
២១. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
២២. អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCDO)
២៣. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
២៤. សហគមន៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍ ដើម្បីពង្រឹងជីវភាព (EDCI)
២៥. អង្គការអប់រំសុខភាព និង បរិស្ថាន (EHE)
២៦. អង្គការសមធម៌កម្ពុជា (EC)
២៧. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC)
២៨. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
២៩. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
៣០. សហគមន៍ព្រៃឈើក្បាលខ្លា (កំពង់ធំ)
៣១. អង្គការក្តីករុណា (KDK)
៣២. អង្គការក្លាហាន (KLAHAAN)
៣៣. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
៣៤. សហគមន៍ជនជាតិដើមភាគតិចកួយ (ព្រះវិហារ)
៣៥. សហគមន៍ជនជាតិដើមភាគតិចកួយឃុំងន (កំពង់ធំ)
៣៦. សហគមន៍ជនជាតិដើមភាគតិចកួយឃុំប្រមេរុ (ព្រះវិហារ)
៣៧. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ (LRSU)
៣៨. សហគមន៍ដីធ្លី (ប៉ៃលិន)
៣៩. សហគមន៍ឡពាង (កំពង់ឆ្នាំង)
៤០. សហគមន៍មានជ័យ (ស្វាយរៀង)
៤១. សមាគមអភិវឌ្ឍន៍ជនជាតិដើមភាគតិចមណ្ឌលគីរី (MIPAD)
៤២. ចលនាមាតាធម្មជាតិ (MNC)
៤៣. សហគមន៍តំបន់ការពារធម្មជាតិឧត្តមស្រែពស់ (កំពង់ស្ពឺ)
៤៤. សហគមន៍អូរបាត់មាន់ (ឧត្តរមានជ័យ)
៤៥. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ (PED Cambodia)
៤៦. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP-Center)

៤៧. សហគមន៍ភ្នំក្រោម (សៀមរាប)
៤៨. អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD)
៤៩. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
៥០. សហគមន៍ពង្រកជ័យល័ក្ខ (កំពត)
៥១. អង្គការពន្លកខ្មែរ (PKH)
៥២. សហគមន៍ព្រៃឈើពេជចង្វារល្អឆើត (កំពង់ឆ្នាំង)
៥៣. បណ្តាញសហគមន៍ព្រៃឡង់ (PLCN)
៥៤. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
៥៥. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
៥៦. អង្គការសមាគមធាងត្នោត (ស.ធ.ត)
៥៧. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
៥៨. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)
៥៩. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
៦០. សមាគម ក្រុមអភិវឌ្ឍន៍ភូមិ (KAWP)
៦១. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)
៦២. សហគមន៍ព្រៃឈើទេសចរណ៍ទឹកធ្លាក់ស្រែអំពិល (កំពង់ឆ្នាំង)
៦៣. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
៦៤. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
៦៥. សមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA)
៦៦. សហគមន៍ដីធ្លី ឃុំត្នោតជុំ (ពោធិ៍សាត់)
៦៧. សហគមន៍ព្រៃឈើត្រពាំងចាន (កំពង់ឆ្នាំង)
៦៨. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
៦៩. សហគមន៍ទន្លូង (ត្បូងឃ្មុំ)
៧០. មជ្ឈមណ្ឌលវិទ្យុស្ត្រីកម្ពុជា (WMC)
៧១. អង្គការលើកកម្ពស់គុណភាពជីវិត (WELL)
៧២. Union for Civil Liberty (UCL)
៧៣. អង្គការស្ត្រីក្រីក្រ (UPWD)